01219129



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 03 / 2016
ម៉ោង (Time/Heure): 13:05
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ចន្ទ ទី ១៨ ខែ មករា ឆ្នាំ ២០១៦

## សវនាការលើភ័ស្តុតាង - ថ្ងៃ ៣៥៨

រៀបចំដោយ៖ **ជា ស៊ីវហ័ង** និង Roger PHILLIPS

| |
|---|
| **កំណត់ហេតុអ្នកចូលរួម** |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា, ចៅក្រម យ៉ា សុខន, ចៅក្រម Martin KAROPKIN |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ័ង , លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន្ត, លោក Travis FARR, លោក សេង លាង, លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| |
|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ពេជ អង្គ, លោក វ៉ែន ពៅ |
| សាក្សី/ដើមបណ្ដឹង៖ 2-TCW-894, 2-TCW-938 |
| មេធាវីប្រឹក្សា៖ លោក មឿន សុវណ្ណ, លោក ម៉ម រិទ្ធា |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី ស្វ សុទ្ធាវី |
| ផ្សេងៗ៖ លោក ឡូញ ង៉ែត, លោក ម៉ៀច សុវណ្ណា, លោក លឿង សូភ័ក្ត, កញ្ញា ស្រី ណាក់, កញ្ញា Elena FAVARO VIANA, លោក កែវ វ៉ាត |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.១០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១៦ | បញ្ចប់ម៉ោង៖ ១០.៣២ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៥៧ | បញ្ចប់ម៉ោង៖ ១៥.១៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៥ ម៉ោង និង ២៨ នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៥ | ០៩.០៧ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៧ | ០៩.១០ |
| ការតាំងសំណួរទៅកាន់សាក្សី 2-TCW-894 | សហមេធាវីនាំមុខ<br>មេធាវីការពារក្ដី នួន ជា<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី នួន ជា<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី ខៀវ សំផន<br>អង្គជំនុំជម្រះ | ០៩.១១<br>០៩.២២<br>១០.៥៤<br>១០.៥៨<br>១១.00<br>១១.០៣<br>១៤.០២ | ០៩.២២<br>១០.៥៣<br>១០.៥៨<br>១០.៥៩<br>១១.០៣<br>១៤.០២<br>១៤.០៣ |

| | | | |
|---|---|---|---|
| សារណាឆ្លើយតបផ្ទាល់មាត់ទៅនឹងសំណើរបស់ធាវីការពារក្តី នួន ជា ដែលស្នើសុំដកសាក្សី 2-TCW-989 ពីបញ្ជីសាក្សីសម្រាប់កិច្ចដំណើរការសវនាការក្នុងសំណុំរឿង ០០២/០២ | អង្គជំនុំជម្រះ | ១៤.០៣ | ១៤.០៦ |
| | សហព្រះរាជអាជ្ញា | ១៤.០៦ | ១៤.១០ |
| | សហមេធាវីនាំមុខ | ១៤.១១ | ១៤.១២ |
| | មេធាវីការពារក្តី ខៀវ សំផន | ១៤.១២ | ១៤.១៤ |
| | មេធាវីការពារក្តី នួន ជា | ១៤.១៥ | ១៤.១៩ |
| | សហព្រះរាជអាជ្ញា | ១៤.២០ | ១៤.២០ |
| | មេធាវីការពារក្តី នួន ជា | ១៤.២០ | ១៤.២០ |
| | អង្គជំនុំជម្រះ | ១៤.២១ | ១៤.២២ |
| ការតាំងសំណួរទៅកាន់សាក្សី 2-TCW-938 | អង្គជំនុំជម្រះ | ១៤.២២ | ១៤.៣៦ |
| | សហព្រះរាជអាជ្ញា | ១៤.៣៦ | ១៦.០៥ |
| ការបញ្ជាក់អំពីឯកសារ E319/39.3.5 ដែលទើបនឹងដាក់បង្ហាញដោយសហព្រះរាជអាជ្ញាទៅកាន់មេធាវីការពារក្តី | សហព្រះរាជអាជ្ញា | ១៥.១៦ | ១៥.២២ |
| | មេធាវីការពារក្តី នួន ជា | ១៥.២២ | ១៥.២៥ |
| | សហព្រះរាជអាជ្ញា | ១៥.២៥ | ១៥.២៥ |
| | សហមេធាវីនាំមុខ | ១៥.២៥ | ១៥.២៥ |
| | មេធាវីការពារក្តី នួន ជា | ១៥.២៥ | ១៥.២៥ |
| | មេធាវីការពារក្តី ខៀវ សំផន | ១៥.២៦ | ១៥.២៨ |
| | សហព្រះរាជអាជ្ញា | ១៥.២៨ | ១៥.៣០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឲ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការតាំងសំណួរទៅកាន់សាក្សី 2-TCW-894**

សហមេធាវីនាំមុខ មេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះ និង មេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរទៅកាន់សាក្សី 2-TCW-894 នៅក្នុងសវនាការជាអសាធារណៈ។

**សារណាឆ្លើយតបផ្ទាល់មាត់ទៅនឹង សំណើរបស់ធាវីការពារក្តី នួន ជា ដែលស្នើសុំដកសាក្សី 2-TCW-989 ពីបញ្ជីសាក្សីសម្រាប់កិច្ចដំណើការ សវនាការក្នុងសំណុំរឿង ០០២/០២**

នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៦ មេធាវីការពារក្តី នួន ជា បានដាក់សំណើសុំដកសាក្សី 2-TCW-989 ចេញពីបញ្ជីសាក្សីដែលត្រូវបានទទួលយកដោយអង្គជំនុំជម្រះដើម្បីមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E346/2/1)។ សហព្រះរាជអាជ្ញា សហមេធាវីនាំមុខ និងមេធាវីការពារក្តី ខៀវ សំផន បានធ្វើសារណាឆ្លើយតបផ្ទាល់មាត់ទៅនឹងសំណើនេះ។ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចក្នុងពេលសមស្របខាងមុខ។

**ការតាំងសំណួរទៅកាន់សាក្សី 2-TCW-938**

អង្គជំនុំជម្រះ និងសហព្រះរាជអាជ្ញា បានតាំងសំណួរទៅកាន់សាក្សី 2-TCW-938 ក្នុងសវនាការជាអសាធារណៈ។

**ការបញ្ជាក់អំពីឯកសារ E319/39.3.5 ដែលទើបនឹងដាក់បង្ហាញដោយសហព្រះរាជអាជ្ញាទៅកាន់ក្រុមមេធាវីការពារក្តី**

អង្គជំនុំជម្រះបានឱ្យសហព្រះរាជអាជ្ញាបញ្ជាក់បន្ថែមអំពីការប្រើប្រាស់របាយការណ៍ស៊ើបអង្កេត ដែលជាឯកសារដែលទើបនឹងដាក់បង្ហាញ (E319/39.3.5) ទៅកាន់ក្រុមមេធាវីការពារក្តី កាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦។ សហព្រះរាជអាជ្ញា បានលើកឡើងថាខ្លួនមិនមានបំណងក្នុងការប្រើប្រាសឯកសារនេះទេ ហេតុនេះមិនបានដាក់សំណើតាមវិធាន ៨៧(៤) នោះឡើយ ប៉ុន្តែខ្លួនយល់ថាព័ត៌មានមួយចំនួននៅក្នុងឯកសារនោះអាចដោះបន្ទុក។ មេធាវីការពារក្តី ខៀវ សំផន បានដាក់សំណើតាមវិធាន ៨៧(៤) ក្នុងការប្រើប្រាស់ឯកសារមួយក្នុងចំណោមឯកសារទាំងនោះ ហើយសហព្រះរាជអាជ្ញាមិនជំទាស់នោះទេ។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខមិនជំទាស់ទៅនឹងការទទួលយករបាយការណ៍នោះទេ។ មេធាវីការពារក្តី នួន ជា ក៏មិនជំទាស់ដែរ ប៉ុន្តែ ស្នើសុំដើម្បីអាចមើលកំណត់ហេតុស្តាប់ចម្លើយទាំង ១៣ ដែលមាននៅក្នុងរបាយការណ៍នោះ។ មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងការប្រើប្រាស់របាយការណ៍នោះដោយសារខ្លួនមិនអាចពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយដែលពាក់ព័ន្ធក្នុងរបាយ-ការណ៍នោះបាន ហើយដែលអ្នកស៊ើបអង្កេតប្រើប្រាស់វិធីសាស្ត្រដែលគួរឱ្យសង្ស័យ។ អង្គជំនុំជម្រះអនុញ្ញាតិឱ្យប្រើប្រាស់របាយការណ៍ស៊ើបអង្កេតនោះនៅក្នុងសវនាការ ប៉ុន្តែបានបង្គាប់ឱ្យសហព្រះរាជ-អាជ្ញារង សួរសំណួរបើក។

## New E3s

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9735 | D219/492 | 01138982-01138989 | Written Record of Investigation Action | P | / | / | / |

## Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9677 | | 01136628-01136635; 01151266-01151273 | Written Record of Interview witness PRAK Yut dated 21-08-2015 | P | 01136630 | 01151268 | / |
| E3/9500 | | 00964450-00964458; 00966985-00966993; 00965589-00965596 | Written Record of Interview of 2-TCW-894 | P | 00964457 | 00966992 | 00965595 |
| E3/9507 | | 01056037-01056066; 01059269-01059302; 01123901-01123925 | Written Record of Interview Witness 2-TCW-894 | P | 01056050; 01056058; 01056056; 01056042-01056043 | 01059284-01059285; 01059293; 01059291; 01059275-01059276 | 01123912; 01123918; 01123917; 01123905-01123906 |
| E3/9499 | | 01046827-01046845; 01063603-01063626; 01106528-01106545 | Written Record of Interview of 2-TCW-938Dated 30-09-2014 | P | 01046832; 01046831-01046832; 01046843 | 01063610; 01063608-01063609; 01063623 | 01106533; 01106532; 01106542 |
| E3/9496 | | 01046800-01046811; 01056221-01056232; 01103656-01103667 | Written Record of Interview of 2-TCW-938Dated 19-06-2013 | P | 01046809; 01046804-01046805; 01046834 | 01056229; 01056225; 01063611-01063612 | 01103664; 01103661; 01106534 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/9462 | | 00893169-00893173; 00903201-00903206; 00974979-00974984 | Written Record of Witness Interview of PECH Chim | P | 00893170-00893171 | 00903203 | 00974980-00974981 |
| E3/9522 | | 01046790-01046798; 01056213-01056220; 01120108-01120115 | Written Record of Interview of 2-TCW-938Dated 28-05-2013 | P | 01046798; 01046794 | 01056219; 01056217 | 01120115; 01120112 |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E1/34.1 | | 00773515-00773606; 00774497-00774610; 00774611-00774730 | Transcript of hearing on the substance in Case 002- 26 January 2012 | P | N/A | 00774583 | 00774701 |
| E3/163 | D234/4 | 00357505-00357516; 00364077-00364086; 00403121-00403129 | [Corrected 1] Written Record of Interview of 2-TCW-938dated 21 July 2009 | P | 00357510 | 00364081 | 00403125 |
| E1/33.1 | | 00773432-00773514; 00774031-00774129; 00774130-00774227 | Transcript of hearing on the substance in Case 002- 25 January 2012 | P | 00773490 00773491 | 00774103 00774105 | 00774202 00774204 |
| E3/2653 | | 00904196-00904430; 00219050-00219245; 00943973-00943985 | YSA Osman, "The Cham Rebellion: Survivor's Stories from the Village", DC-Cam, 2006. | P | 00904407 | 00219210 | / |

| ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖ |
| --- |
| • អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.១០)<br>• បង្គាប់អនុញ្ញាតិឱ្យប្រើប្រាស់ឯកសារ E319/39.3.5។ (១៥.៣០)<br>• បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦។ (១៤.០៩) |

| កាលវេលាសវនាការបន្ត |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

**ជា ស៊ីវហ៊ាង** Roger PHILLIPS